**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីថ្លែងការណ៍

## ថ្កោលទោសជនក្បត់ជាតិ៣ ជំនាន់ សម រង្ស៊ី ដែលបន្តប្រមាថព្រះមហាក្សត្រ យ៉ាងធ្ងន់ធ្ងរបំផុត

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងការបរទេស និងសហប្រតិបត្តិការជាតិអន្តរជាតិ ព្រមទាំងមន្ត្រីការទូតទាំងអស់ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេស សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទណ្ឌិតក្បត់ជាតិបីជំនាន់ សម រង្ស៊ី ដែលបានប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃប្រជារាស្ត្រខ្មែរគ្រប់រូប ។

ទង្វើទុច្ចរិតរបស់ទណ្ឌិតក្បត់ជាតិ សម រង្ស៊ី ដែលប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតចំពោះ អង្គព្រះមហាក្សត្រ ព្រះប្រមុខរដ្ឋ និងជាអគ្គមហារដ្ឋបុរសស្នេហាជាតិដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់ គឺជាទោសពុំអាចលើកលែងបាន និងបានរំលោភលើមាត្រាទី៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា "អង្គព្រះមហាក្សត្រ មិនអាចនរណាមករំលោភបំពានបានឡើយ"។

យើងខ្ញុំទាំងអស់គ្នា សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការចំពោះគំនិតដ៏អាក្រក់ និងគ្មានសីលធម៌របស់ទណ្ឌិតក្បត់ជាតិ សម រង្ស៊ី និងសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ចាត់វិធានការតាមផ្លូវច្បាប់ ឱ្យបានម៉ឺងម៉ាត់ជាទីបំផុតទៅលើទណ្ឌិតរូបនេះ ព្រមទាំងបក្សពួក ដែលបានប្រមាថដ៏ធ្ងន់ធ្ងរបំផុតលើ អង្គព្រះមហាក្សត្រ ដោយមិនអាចអត់ឱនឱ្យបានជាដាច់ខាត។

ទន្ទឹមនឹងនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការចាត់វិធានការលប់បំបាត់ចោលមនោគមវិជ្ជានយោបាយជ្រុលនិយមរបស់ទណ្ឌិតក្បត់ជាតិបីជំនាន់ សម រង្ស៊ី ដើម្បីរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ៕

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២២

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh